# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

**រវាងក្រុមហ៊ុន យីងសិនសេងព្រីនធីង ឯ.ក និងជាមួយតំណាងកម្មករប្រតិភូបុគ្គលិក**

**និង ប្រធានក្រុម ប្រចាំក្រុមហ៊ុន**

កម្មវត្ថុ: កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២៣ វេលាម៉ោង ២ រសៀល ០០នាទី នៅក្រុមហ៊ុន យីងសិនសេងព្រីនធីង ឯ.ក មាន កិច្ចប្រជុំជាមួយ តំណាងក្រុមហ៊ុន និង តំណាង កម្មករនិយោជិត។

នៅអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានជូនដំណឹង ជម្រាបដល់បងប្អូនកម្មករ និយោជិតទាំងអស់គ្នា ស្តីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុន ដែលខ្វះការបញ្ជារទិញ បណ្តាលអោយក្រុមហ៊ុនយើងបានផ្អាកតំណើរការនៃការផលិត ។

ដូច្នេះក្រុមហ៊ុនបានសម្រេចចិត្ត ព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ចំនួន១៦នាក់(ស្រី១១នាក់)ក្នុងចំណោមកម្មករនិយោជិតសរុប ៥៣នាក់(ស្រី ២៧)នាក់ ដោយគិតពីថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២៣។

ក្នុងអំឡុងពេលព្យួរកិច្ចសន្យារយៈពេល ២៦ ថ្ងៃ ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថមចំនួន ៣០ដុល្លារអាម៉េរិច ដោយមានការឯកភាពផងដែរពីប្រតិភូបុគ្គលិក និង កម្មករនិយោជិត ការបើកប្រាក់៣០ដុល្លារអាម៉េរិច ជូនពួកគាត់នៅថ្ងៃទី ០៥ កក្កដា ឆ្នាំ២០២៣។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ៣ : ៤៥ នាទី នារសៀលថ្ងៃខែឆ្នាំដដែលប្រកបដោយ បរិយាកាសរីករាយ និងស្និតស្នាល ក្រោមស្មារតី ទទួលខុសត្រូវខ្ពស់និង យោគយល់សហការគ្នាយ៉ាងរលូន។

**ស្នាមមេដៃកម្មករនិយោជិត**

**តំណាងក្រុមហ៊ុន**

ថ្ងៃអង្គារ ១០ កើត ខែបឋមាសាឍ ឆ្នាំថោះ

បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យីង សិន សេង ព្រីនធីង ឯ.ក KING SEN SHENG PRINTING CO.,LTD. KINGDOM OF CAMBODIA

SAT VOEUN